# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់**
**គណៈកម្មការសុរិយោដីថ្នាក់ជាតិ**

លេខ : ០៣៦ ប្រក.ដនស/គសជ

## ប្រកាស
## ស្តីពី
## ការធ្វើប្រតិភូកម្មមុខងារជូនអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត និងជាប្រធានគណៈកម្មការសុរិយោដីរាជធានី ខេត្ត ដើម្បីធ្វើសេចក្តីសម្រេចលើសំណុំរឿងវិវាទដីធ្លីក្នុងយន្តការរបស់គណៈកម្មការសុរិយោដី

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១០៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ៦២អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៤៧អនក្របក. ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី
- បានឃើញអនុក្រឹត្យលេខ ៣៤អនក្រ.បក. ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៦ ស្តីពីការកែប្រែមាត្រា ៥ និងមាត្រា ២៨ នៃអនុក្រឹត្យលេខ ៤៧អនក្របក. ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី

- បានឃើញប្រកាសលេខ ១១២ជនស.ប្រក ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២ ស្ដីពីគោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដី
- បានឃើញប្រកាសអន្តរក្រសួងលេខ ០២ប្រករ.០៣. ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្ដីពីការកំណត់ភារកិច្ចរបស់តុលាការ និងគណៈកម្មការសុរិយោដីពាក់ព័ន្ធនឹងរឿងវិវាទដីធ្លី
- បានឃើញសេចក្ដីណែនាំរួមលេខ ០៥សណន. ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៦ ស្ដីពីការអនុវត្តន៍អនុក្រឹត្យលេខ ៣៤អនក្រ.បក ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៦
- យោងសេចក្ដីជូនដំណឹងលេខ១៦៧៤ សជណ.ខុស. ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ ២០០៩ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី

## <u>ស ម្រេ ច</u>

**ប្រការ១ :** ត្រូវបានធ្វើប្រតិភូកម្មមុខងារជូនអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត និងជាប្រធានគណៈកម្មការសុរិយោដីរាជធានី ខេត្ត ដើម្បីធ្វើសេចក្ដីសម្រេចលើករណីវិវាទដីធ្លីក្នុងយន្តការរបស់គណៈកម្មការសុរិយោដី ។

**ប្រការ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ៣ :** នាយកខុទ្ទកាល័យ ប្រធានលេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ គណៈកម្មការសុរិយោដីរាជធានី ខេត្ត ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ប្រធានលេខាធិការដ្ឋានគណៈកម្មការសុរិយោដីរាជធានី ខេត្ត ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែ មករា ឆ្នាំ២០១០

ទេសរដ្ឋមន្ត្រី

អ៊ឹម ឈុនលឹម

**<u>កន្លែងទទួល</u>**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
- គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- សមាជិកគណៈកម្មការសុរិយោដីថ្នាក់ជាតិ
- សមាជិកគណៈកម្មការសុរិយោដីរាជធានី ខេត្ត
- ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
- គ្រប់អគ្គនាយកដ្ឋាន និងអង្គភាពជុំវិញក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ដូចប្រការ ៣
- រាជកិច្ច
- ក្រុមការងារគេហទំព័រក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់
- ឯកសារ-កាលប្បវត្តិ